# ច្បាប់

## ស្តីពី

## ការពិនិត្យ និង ដោះស្រាយបណ្តឹងតវ៉ា
## និង បណ្តឹងបរិហារ របស់ពលរដ្ឋ

## ជំពូក ទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១** - ត្រូវបង្កើតឱ្យមានការត្រួតពិនិត្យរបស់ប្រជាជន ចំពោះអង្គការរដ្ឋ អង្គការសង្គម អង្គភាពកងកម្លាំងប្រដាប់អាវុធប្រជាជន និង ចំពោះ បុគ្គល នៃអង្គការទាំងនោះ សំដៅ៖

- កសាងទំនាក់ទំនងដ៏ត្រឹមត្រូវរវាងចក្រ រដ្ឋអំណាច និងប្រជាជន។

- ពង្រឹងនីត្យានុកូលភាពសង្គមនិយម។

- ការពារផលប្រយោជន៍រដ្ឋ និង សមូហភាព និង ផលប្រយោជន៍ស្របច្បាប់របស់ពលរដ្ឋ។

- ធានាសិទ្ធិប្តឹងតវ៉ា និង សិទ្ធិប្តឹងបរិហារ របស់ពលរដ្ឋ ។

- កំណត់ករណីយកិច្ច និង លើកកំពស់ការទទួលខុសត្រូវរបស់ប្រធាន

អង្គការរដ្ឋ អង្គការសង្គម អង្គភាពកងកម្លាំងប្រដាប់អាវុធប្រជាជន និង បុគ្គល នៃអង្គការទាំងនោះ ក្នុងការពិនិត្យនិងដោះស្រាយបណ្តឹងតវ៉ា និង បណ្តឹង បរិហាររបស់ពលរដ្ឋ។

**មាត្រា ២** - ពលរដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា មានសិទ្ធិប្តឹង និងលើកមតិស្នើដល់អង្គការរដ្ឋណាមួយក៏បាន អំពីអំពើខុសឆ្គងនឹងគោលនយោបាយ ឬ ច្បាប់ ដែលប្រព្រឹត្តដោយអង្គការរដ្ឋ អង្គការសង្គម អង្គភាពកងកម្លាំងប្រដាប់អាវុធប្រជាជន ឬបុគ្គលណាមួយ នៃអង្គការទាំងនោះ ដែលបង្កអន្តរាយដល់ផលប្រយោជន៍របស់រដ្ឋ សមូហភាព ឬផលប្រយោជន៍ ស្របច្បាប់ របស់ពលរដ្ឋ ។

**មាត្រា ៣** - អង្គការរដ្ឋ អង្គការសង្គម អង្គភាពកងកម្លាំងប្រដាប់អាវុធ ប្រជាជន មានកាតព្វកិច្ចពិនិត្យ និង ដោះស្រាយបណ្តឹងតវ៉ា បណ្តឹងបរិហារ និង សំណើរបស់ពលរដ្ឋ ឱ្យបានត្រឹមត្រូវតាមគោលនយោបាយ និង ច្បាប់ ត្រូវស្វះស្វែងរកឱ្យឃើញនូវមូលហេតុ ដែលនាំឱ្យមានការប្តឹងតវ៉ា ឬ ប្តឹងបរិហារ ដើម្បីជួយឱ្យអង្គការរដ្ឋ អង្គការសង្គម ឬ បុគ្គលណាមួយ នៃអង្គការទាំងនោះ ដែលប្រព្រឹត្តខុសឆ្គង កែខ្លួនឡើងវិញ។

អង្គការរដ្ឋ អង្គការសង្គម អង្គភាពកងកម្លាំងប្រដាប់អាវុធ ប្រជាជន ឬ បុគ្គល ដែលត្រូវគេ ប្តឹងបរិហាមានភារកិច្ចអនុវត្តគ្រប់វិធានការ ដើម្បីកែលំអឡើងវិញ នូវអំពើខុសឆ្គងនោះ ឱ្យបានទាន់ពេលវេលាតាមសេចក្តីសំរេចនៃអង្គការរដ្ឋ ដែលមានសមត្ថកិច្ច។

ហាមឃាត់ដាច់ខាត នូវសកម្មភាពទាំងឡាយណាដែលធ្វើឱ្យរាំងស្ទះបណ្តឹងតវ៉ា បណ្តឹងបរិហាររបស់ពលរដ្ឋ ឬ សងសឹកដល់អ្នកដែលប្តឹងតវ៉ា ឬ ប្តឹងបរិហារ។

ហាម៉ឃាត់ដាច់ខាត មិនឱ្យជួយបិទបាំងអង្គការរដ្ឋ អង្គការសង្គម អង្គភាពកងកម្លាំងប្រដាប់អាវុធប្រជាជន ឬ បុគ្គល នៃអង្គការទាំងនោះ ដែលត្រូវគេប្តឹងបរិហារ។

**មាត្រា ៤** - ជនរងគ្រោះ ត្រូវបានជួសជុលឡើងវិញខាងផ្លូវចិត្ត ឬ ជួសជុលនូវអ្វីៗ ដែលត្រូវអន្តរាយតាមកំណត់នៃច្បាប់ជាធរមាន អង្គការរដ្ឋ អង្គការសង្គម អង្គភាពកងកម្លាំងប្រដាប់អាវុធប្រជាជន ឬ បុគ្គល នៃអង្គការទាំងនោះ ដែលបានធ្វើឱ្យអន្តរាយដល់អ្នកដទៃ ត្រូវជួសជុលឡើងវិញនូវអ្វីៗ ដែលខ្លួនបានបង្កឱ្យអន្តរាយ។

**មាត្រា ៥** - អង្គការមានសមត្ថកិច្ច ត្រូវសហការជាមួយនឹងអង្គការដែល មានទំនាក់ទំនងក្នុងការពិនិត្យ និងដោះស្រាយការប្តឹងតវ៉ា ឬ ការប្តឹងបរិហារ។

## ជំពូកទី ២

## ការទទួលបណ្តឹងតវ៉ា និង បណ្តឹងបរិហារ

**មាត្រា ៦**- ពលរដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា អាចធ្វើបណ្តឹង ឬមកកាន់អង្គការរដ្ឋណាមួយដោយផ្ទាល់ ដើម្បីប្តឹងតវ៉ា ឬ ប្តឹងបរិហារ ការរដ្ឋទាំងនោះ ត្រូវមានភារកិច្ចទទួលបណ្តឹង របស់អ្នកដែលបកប្តឹងតវ៉ា ឬ ប្តឹងបរិហារ។

អង្គការដ្ឋ និង អង្គការសង្គម ពីមជ្ឈឹមដល់ថ្នាក់ស្រុក និង សង្កាត់ ក្រុង ត្រូវកំណត់របបទទួលពាក្យបណ្តឹងរបស់ប្រជាជន។ ពេលវេលា និង ទីកន្លែង ដែលត្រូវទទួលរួមប្រាស្រ័យជាមួយប្រជាជន ត្រូវផ្សាយជាសាធារណៈ។

អង្គការដែលទទួលបណ្តឹងតវ៉ា ឬ បណ្តឹងបរិហារ ត្រូវកត់ត្រានូវខ្លឹមសារនៃ បណ្តឹងតវ៉ា ឬ បណ្តឹងបរិហារនោះ ចូលក្នុងបញ្ជីទទួលពាក្យបណ្តឹង។ ប្រសិនបើសាមីខ្លួន មកប្តឹងដោយផ្ទាល់មាត់នោះ ត្រូវកត់ត្រាឱ្យបានត្រឹមត្រូវ និងម៉ត់ចត់ នូវខ្លឹមសារនៃបណ្តឹង ហើយត្រូវឱ្យម្ចាស់បណ្តឹង ចុះហត្ថលេខាបញ្ជាក់ការតវ៉ា ឬ ការបរិហារ លើលិខិតកត់ត្រានោះ។

ប្រសិនបើ អង្គការ ដែលទទួលពាក្យបណ្តឹង ពិនិត្យឃើញថា ការដោះស្រាយបណ្តឹងតវ៉ា ឬ បណ្តឹងបរិហារ មិនមែនជាសមត្ថកិច្ចរបស់ខ្លួនទេ ត្រូវផ្ញើពាក្យបណ្តឹងនោះ ទៅអង្គការដែលមានសមត្ថកិច្ច ដើម្បីពិនិត្យ និងដោះស្រាយ ហើយត្រូវជូនដំណឹងដល់ម្ចាស់បណ្តឹងឱ្យបានដឹងពីរឿងនេះ។ ប៉ុន្តែបើសាមីខ្លួន មកប្តឹងតវ៉ា ឬ ប្តឹងបរិហារដោយផ្ទាល់មាត់នោះ ប្តឹងដល់អង្គការមានសមត្ថកិច្ចវិញ។

**មាត្រា ៧** - ហាមឃាត់ដាច់ខាតនូវអំពើដែលធ្វើឱ្យបែកការសម្ងាត់ ឬ បង្វែរពាក្យបណ្តឹងបរិហារ ចម្លងពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ឬ ជាខ្សែអាត់ ឱ្យទៅអង្គការ ឬ បុគ្គល ដែលត្រូវគេប្តឹងបរិហារ ឱ្យដឹងឡើយ។

មិនត្រូវបញ្ជូនពាក្យបណ្តឹងតវ៉ាទៅឱយអង្គការ ឬ បុគ្គល ដែលត្រូវគេប្តឹង ទេ ប្រសិនបើយល់ឃើញថា អាចនឹងបណ្តាលឱយមានផលអាក្រក់ដល់ម្ចាស់បណ្តឹង។

## សមត្ថកិច្ច និង ឋិរវលាពិនិត្យ និង

## ដោះស្រាយបណ្តឹងតវ៉ា និង បណ្តឹងបរិហារ

**មាត្រា ៨** - ការប្តឹងតវ៉ាចំពោះបុគ្គល ដែលឋិតនៅក្នុងក្របខ័ណ្ឌ នៃ អង្គការណាមួយ ត្រូវប្រធាន ឬ គណៈដឹកនាំនៃអង្គការនោះ ជាអ្នកមានភារកិច្ចពិនិត្យ និង ដោះស្រាយ។

ការប្តឹងតវ៉ាចំពោះប្រធាន ឬ គណៈដឹកនាំនៃអង្គការណាមួយ ត្រូវប្រធាន ឬ គណៈដឹកនាំថ្នាក់លើ ដែលដឹកនាំអង្គការនោះផ្ទាល់ ជាអ្នកមានភារកិច្ចពិនិត្យ និង ដោះស្រាយ។

**មាត្រា ៩** - ការប្តឹងបរិហារចំពោះបុគ្គល ដែលឋិតនៅក្នុងក្របខ័ណ្ឌអង្គការណាមួយ ត្រូវប្រធាន ឬ គណៈដឹកនាំថ្នាក់លើនៃអង្គការនោះ ជាអ្នកមានភារកិច្ចពិនិត្យ និង ដោះស្រាយ។

ការប្តឹងបរិហារចំពោះប្រធាន ឬ គណៈដឹកនាំនៃអង្គការណាមួយ ដោយយោងទៅតាមស្ថានភាពនៃការប្តឹងបរិហារ ត្រូវប្រធាន ឬ គណៈដឹកនាំថ្នាក់លើ ដែលដឹកនាំអង្គការនោះផ្ទាល់ ឬក៏ថ្នាក់ប្រធាន ឬ គណៈដឹកនាំថ្នាក់លើខ្ពស់ជាង អង្គការនោះមួយថ្នាក់ ជាអ្នកមានភារកិច្ចពិនិត្យ និង ដោះស្រាយ។

**មាត្រា ១០** - ក្រោយពេលដែលអង្គការមានសមត្ថកិច្ចបានពិនិត្យ និងមាត្រា១០ ដោះស្រាយរួចហើយ ប៉ុន្តែ សាមីខ្លួនមិនយល់ព្រមនោះសាមីខ្លួន អាចបន្តការ ប្តឹងតវ៉ា ឬ ប្តឹងបរិហារទៅថ្នាក់លើ ដែលដឹកនាំផ្ទាល់នៃអង្គការទាំងនោះបាន។

**មាត្រា ១១** - អង្គការដែលមានភារកិច្ចពិនិត្យ និង ដោះស្រាយបណ្តឹងតវ៉ា ឬ បណ្តឹងបរិហារ មានសិទ្ធិស្នើដល់អង្គការ ដែលមានការទាក់ទងក្នុងរឿង នេះឱ្យផ្តល់ឯកសារចាំបាច់មកឱ្យខ្លួន អង្គការដែលត្រូវគេស្នើផ្លូវឆ្លើយតបនឹងសំណូមពរទាំងនោះ។

**មាត្រា ១២** - ប្រធានគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត ឬ ក្រុង មានភារកិច្ចពិនិត្យ និង ដោះស្រាយបណ្តឹងតវ៉ា ឬ បណ្តឹងបរិហារ ដែលប្រធាន អង្គការនានានៅក្រោមឱវាទ ឬ ប្រធានគណៈកម្មាធិការប្រជាជនបដិវត្តថ្នាក់ក្រោម បានពិនិត្យ និង ដោះស្រាយរួចហើយ ប៉ុន្តែ សាមីខ្លួនមិនសុខចិត្ត។

រដ្ឋមន្ត្រី ប្រធានស្ថាប័នទាំងឡាយ ដែលឋិតនៅក្រោមឱវាទផ្ទាល់ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី មានភារកិច្ចពិនិត្យ និង ដោះស្រាយបណ្តឹងតវ៉ា ឬ បណ្តឹង បរិហារដែលប្រធានអង្គការនៅក្រោមឱវាទបានពិនិត្យ និង ដោះស្រាយរួចហើយ ប៉ុន្តែសាមីខ្លួនមិនសុខចិត្ត។

**មាត្រា ១៣** - ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី មានភារកិច្ចពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា ឬ បណ្តឹងបរិហាដូចតទៅះ

ក - ការប្តឹងតវ៉ា ឬ ប្តឹងបរិហារចំពោះរដ្ឋមន្ត្រីប្រធានស្ថាប័នទាំងឡាយដែលនៅក្រោមឱវាទផ្ទាល់របស់ករុមប្រឹក្សារដ្ឋមន្ត្រី ប្រធានគណៈកម្មាធិកាប្រជាជនបដិវត្តខេត្ត ក្រុង។

ខ - ការប្តឹងតវ៉ា ឬ ការប្តឹងបរិហា ឡាយដែលរដ្ឋមន្ត្រី ប្រធានស្ថាប័នទាំងឡាយ ដែលនៅក្រោមឱវាទផ្ទាល់របស់ក្រុមប្រឹក្សារដបន្ត្រី ប្រធានគណ់ាកម្មាធិការប្រជាជនបដិវត្តខេត្ត ក្រុង បានពិនិត្យ និង ដោះស្រាយរួចហើយ ប៉ុន្តែមាន ការភ័ន្តច្រឡំ។

**មាត្រា ១៤** - រដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យកិច្ចការ មានភារកិច្ចពិនិត្យ ហើយដាក់ជូនក្រុមប្រឹក្សារដ្ឋមន្ត្រី ដើម្បីពិនិត្យ និង ដោះស្រាយ នូវបណ្ដឹងតវ៉ា ឬ បណ្ដឹងបរិហារ ដែលមានកំណត់ក្នុងមាត្រា ១៣ នៃច្បាប់នេះ។

អង្គការត្រួតពិនិត្យនៅតាមមូលដ្ឋាន នៅតាមក្រសួង និងនៅតាមស្ថាប័ន ទាំងឡាយ ដែលស្ថិតនៅក្រោមឱវាទផ្ទាល់របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី មានភារកិច្ច ជួយប្រធានគណៈកម្មាធិការប្រជាជនបដិវត្ត រដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នរបស់ខ្លួន ក្នុងការត្រួតពិនិត្យ និង ដោះស្រាយបណ្ដឹងតវ៉ា ឬ បណ្ដឹងបរិហារ ដែលបាន កំណត់ក្នុងមាត្រា ១២ នៃច្បាប់នេះ។

**មាត្រា ១៥** - ពាក្យបណ្ដឹងតវ៉ា ឬ បណ្ដឹងបរិហារ បើពិនិត្យទៅឃើញថា មិនមែនជារឿងរដ្ឋបាលទេ អង្គការរដ្ឋ អង្គការសង្គម ត្រូវបញ្ជូនទៅអយ្យការ អមតុលាការ និងតុលាការ ដើម្បីពិនិត្យ និង វិនិច្ឆ័យតាមច្បាប់ជាធរមាន។

**មាត្រា ១៦** - អង្គការមហាជន និង សហគមនានា មានភារកិច្ចពិនិត្យ និង ដោះស្រាយបណ្ដឹងតវ៉ា និង បណ្ដឹងបរិហារចំពោះសមាជិក តាមកំណត់នៃលក្ខន្តិកៈរបស់ខ្លួន។

ចំពោះបណ្ដឹងតវ៉ា ឬ បណ្ដឹងបរិហារ ដែលមិនទាក់ទងនឹងបទបញ្ញត្តិណាមួយនៃលក្ខន្តិកៈ នោះត្រូវបញ្ជូនបណ្ដឹងនោះ ឱ្យទាន់ពេលវេលា ទៅអង្គការមានសមត្ថកិច្ច ដើម្បីពិនិត្យ និង ដោះស្រាយ។

**មាត្រា ១៧** - បណ្ដឹងតវ៉ា ដែលស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់ថ្នាក់ស្រុក សង្កាត់, ត្រូវពិនិត្យ និង ដោះស្រាយក្នុងរយៈមួយខែយ៉ាងយូរ គិតពីថ្ងៃដែលបាន ទទួលបណ្ដឹង ចំពោះខេត្ត ក្រុង និង បញ្ឈិម មិនត្រូវឱយលើសពីបីខឡើយ។

បណ្ដឹងបរិហារ ដែលស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់ថ្នាក់ស្រុក សង្កាត់ ត្រូវពិនិត្យ និង ដោះស្រាយក្នុងរយៈពីរខែយ៉ាងយូរ គិតពីថ្ងៃដែលបានទទួល បណ្ដឹង។ ចំពោះខេត្ត ក្រុង និង មជ្ឈឹម មិនត្រូវយលើសពី ៦ ខែឡើយ។

ចំពោះសំណុំរឿងដែលមានភាពស្មុគស្មាញ ហើយត្រូវការស៊ើបអង្កេតយូរ នោះអង្គការដែលមានសមត្ថកិច្ច ត្រូវធ្វើសេចក្ដីរាយការណ៍ជូនថ្នាក់លើដែលដឹកនាំផ្ទាល់ ដើម្បីសុំពន្យារពេល។

ប៉ុន្តែ ការសុំពន្យារពេលនេះ មិនត្រូវឱ្យ លើសពីពីរដង នៃថិរវេលាដែលបានកំណត់ខាងលើឡើយ។

## ជំពូកទី ៤

## ការគ្រប់គ្រង និង ត្រួតពិនិត្យ នៃការងារពិនិត្យ

## និង ដោះស្រាយបណ្ដឹងតវ៉ា និង បណ្ដឹងបរិហារ

**មាត្រា ១៨** - ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវគ្រប់គ្រងទូទាំងប្រទេស អំពីការងារពិនិត្យ និងដោះស្រាយបណ្ដឹងតវ៉ា និងបណ្ដឹងបរិហាររបស់ពលរដ្ឋ នៃនាំគ្រើនរំលឹក និង ត្រួតពិនិត្យទីស្ដីការរដ្ឋមន្ត្រី ស្ថាប័នដែលស្ថិតក្រោមឱវាទផ្ទាល់របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និង គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត ក្រុង ក្នុងការពិនិត្យ និង ដោះស្រាយបណ្ដឹងតវ៉ា និង បណ្ដឹងបរិហារ។

រដ្ឋមន្ត្រី ប្រធានស្ថាប័នទាំងឡាយដែលស្ថិតនៅក្រោមឱវាទផ្ទាល់របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី មានភារកិច្ចគ្រប់គ្រង ណែនាំ ក្រើនរំលឹក និង ត្រួតពិនិត្យ អង្គការនានា ដែលនៅក្រោមឱវាទរបស់ខ្លួនអំពីការងារពិនិត្យ និងដោះស្រាយ នូវការប្តឹងតវ៉ា និង ការប្តឹងបរិហាររបស់ពលរដ្ឋ។

គណៈកម្មាធិការប្រជាជនបដិវត្ត ត្រូវគ្រប់គ្រងក្នុងក្របខ័ណ្ឌមូលដ្ឋានរបស់ខ្លួន អំពីការងារពិនិត្យ និងដោះស្រាយការប្តឹងតវ៉ា និង ការប្តឹងបរិហាររបស់ ពលរដ្ឋ ណែនាំ ក្រើនរំលឹក និង ត្រួតពិនិត្យអង្គការនានា ដែលនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ក្នុងការពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា និង បណ្តឹងបរិហារ។

**មាត្រា ១៩** - សមាជិករដ្ឋសភា កាលបើបានទទួលបណ្តឹងតវ៉ា ឬ បណ្តឹងបរិហាររបស់ពលរដ្ឋ ត្រូវពិនិត្យ និង បញ្ជូនបណ្តឹងនោះទៅអង្គការមានសមត្ថកិច្ច ដើម្បីដោះស្រាយ។

អង្គការមានសមត្ថកិច្ចខាងលើនេះ ត្រូវរាយការណ៍ជូនសមាជិករដ្ឋសភា អំពីលទ្ធផល នៃការដោះស្រាយបណ្តឹងតវ៉ា ឬ បណ្តឹងបរិហារនោះ។

**មាត្រា ២០** - ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវរាយការណ៍ជាប្រចាំ ជូនក្រុមប្រឹក្សារដ្ឋ អំពីការងារពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា និង បណ្តឹងបរិហារ របស់ពលរដ្ឋ។

**មាត្រា ២១** - រដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ អង្គការត្រួតពិនិត្យ នៅតាមទីស្តីការរដ្ឋមន្ត្រី ស្ថាប័ននានា ដែលស្ថិតក្រោមឱវាទផ្ទាល់ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និង អង្គការត្រួតពិនិត្យនៅតាមមូលដ្ឋាន មានភារកិច្ចណែនាំ ក្រើនរំលឹក និង ត្រួតពិនិត្យការទទួលបណ្តឹង បណ្តឹងបរិហារ និង ការទទួល ប្រជាជន ហើយត្រួតពិនិត្យការដោះស្រាយ នូវបណ្តឹងតវ៉ា និង បណ្តឹងបរិហារ របស់ពលរដ្ឋ ព្រមទាំងមានសិទ្ធិធ្វើសំណូមពរដល់អង្គការដែលមានការទាក់ទង នឹងបណ្តឹងនោះ ឱ្យអនុវត្តគ្រប់វិធានការចាំបាច់ ដើម្បីរារាំងអំពើល្មើសដែលនាំឱ្យមានការប្តឹងផ្តល់។

## ជំពូកទី ៥

## ទោសប្បញ្ញត្តិ និង បទបញ្ញត្តិអនុវត្ត

**មាត្រា ២២** - ជនណា ដែលមានភារកិច្ចទទួលពិនិត្យដោះស្រាយ និង បញ្ជូនពាក្យបណ្តឹងតវ៉ា បណ្តឹងបរិហាររបស់ពលរដ្ឋតែមិនបំពេញភារកិច្ចរបស់ខ្លួន និងជនណាដែលសំអាងលើមុខងារអំណាចរបស់ខ្លួន ហើយរារាំងការប្តឹង តវ៉ា ការប្តឹងបរិហារ ការពិនិត្យ និង ការដោះស្រាយ ឬ មិនអនុវត្តដោយចេតនា តាមការសំរេចរបស់អង្គការមានសមត្ថកិច្ច ហើយបញ្ហាឱ្យខូចប្រយោជន៍ ដល់អ្នកប្តឹងនោះ ត្រូវទទួលទណ្ឌកម្មតាមច្បាប់រដ្ឋបាល គឺ ត្រូវព្រមាន ស្តីបន្ទោស បញ្ចុះថ្នាក់ បញ្ចុះមុខងារ ឱ្យលាឈប់ធ្វើការដោយបង្ខំ ឬ បណ្តេញចោល។

**មាត្រា ២៣** - ជនណា ប្រព្រឹត្តអំពើសងសឹកដល់អ្នកប្តឹងតវ៉ា ឬ អ្នកប្តឹង បរិហា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៣ខែ រហូតដល់ ៣ ឆ្នាំ។

បើអំពើសងសឹក ចូលជាបទល្មើសព្រហ្មទណ្ឌណាមួយដែលមានកំណត់ ក្នុងច្បាប់ជាធរមាន នោះជនប្រព្រឹត្តបទល្មើស នឹងត្រូវផ្តន្ទាទេសតាមច្បាប់ជាធរមាននេះ។

**មាត្រា ២៤** - ជនណា ឆ្លៀតយកសិទ្ធិប្តឹងបរិហាររបស់ខ្លួន ប្តឹងបរិហារ មួលបង្កាច់ដោយចលនាដល់អ្នកដៃ ដល់អង្គការរដ្ឋ ឬ អង្គការណាមួយ ត្រូវបានផ្តន្ទាទោសតាមច្បាប់។

**មាត្រា ២៥** - ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលបន្ទុកណែនការអនុវត្តន៍ច្បាប់នេះ។

ច្បាប់នេះ រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានអនុម័ត នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៨២ សម័យប្រជុំលើកទី ៣ នីតិកាលទី១។

ប្រធានរដ្ឋសភា

ហត្ថលេខា និង ត្រា

**ជា ស៊ីម**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ១៩៨២

អគ្គលេខាធិការក្រុមប្រឹក្សារដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ម៉ែន ឆន**